មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# របាយការណ៍ប្រចាំឆ្នាំ២០១៥ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

| | |
|---|---|
| **ឈ្មោះស្ថាប័ន** | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) |
| **គោលដៅ** | ទស្សនៈវិស័យរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាគឺកម្ពុជាគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសិទ្ធិស្មើគ្នា និងត្រូវបានផ្តល់អំណាច ដើម្បីចូលរួមក្នុងលិទ្ធិប្រជាធិបតេយ្យនិងទទួលបាន ការចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍប្រទេសកម្ពុជា។ |
| **រយៈពេល** | ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៥ |

## ១. សេចក្តីផ្តើម

បញ្ហាសិទ្ធិមនុស្សនៅកម្ពុជាមានការវិវឌ្ឍន៍ដែលគួរឱ្យព្រួយបារម្ភមួយចំនួននៅឆ្នាំ២០១៥។ ទោះបីប្រទេសកម្ពុជាបន្តនូវការអភិវឌ្ឍន៍សេដ្ឋកិច្ច ក៏របត់ទូទៅនៃស្ថានភាពសិទ្ធិមនុស្សនៅតែបន្តពីឆ្នាំ២០១៤ ទៅលើការរឹតត្បិតបន្ថែមទៀតផ្នែកសិទ្ធិមនុស្ស។ រាជរដ្ឋាភិបាលកម្ពុជាកំពុងរៀបចំការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧ និងបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៨ ដោយរឹតបន្តឹងទៅលើជីវភាពសាធារណៈនិងប៉ុនប៉ងគាបសង្កត់ទៅលើសំឡេងជំទាស់។ រាជរដ្ឋាភិបាលតែងខកខាននិងបំពានសិទ្ធិដែលមាននៅចែងនៅរដ្ឋធម្មនុញ្ញរបស់កម្ពុជានិងបទដ្ឋានអន្តរជាតិ ជាពិសេសការរឹតត្បិតទៅលើសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយមូលដ្ឋានដូចជាសេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងសមាគម និងសេរីភាពខាងការជួបប្រជុំ។ សិទ្ធិផ្សេងទៀត ដូចជាសិទ្ធិដីធ្លីក៏ត្រូវបានរឹតត្បិតក្រោមប្រព័ន្ធច្បាប់និងគោលនយោបាយរបស់រដ្ឋាភិបាលបច្ចុប្បន្ន។ ការរំលោភបំពានសិទ្ធិមនុស្សទាំងនេះកើតឡើងដោយសារតែកង្វះការអនុវត្តន៍ច្បាប់ដែលមិនអនុលោតាមបទដ្ឋានសិទ្ធិមនុស្ស និងតាមរយៈការសម្រេចចិត្តរបស់រដ្ឋាភិបាលនិងវិធានការផ្ទាល់របស់អាជ្ញាធរជាតិនិងថ្នាក់មូលដ្ឋាន។ បញ្ហាទាំងអស់នេះបង្កឡើងដោយសារតែកង្វះប្រព័ន្ធតុលាការឯករាជ្យដែលនៅតែកើតមាន។

បញ្ហាសិទ្ធិមនុស្សមួយដ៏ចំបងដែលកើតឡើងនៅឆ្នាំ២០១៥ គឺការដាក់ឲ្យដំណើរការច្បាប់ចេញថ្មីមួយស្តីអំពីច្បាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលបានអនុម័តនៅខែសីហា បន្ទាប់ពីរងការរិះគន់ជាច្រើនឆ្នាំព្រមទាំងមិនមានការពិគ្រោះយោបល់ឲ្យបានពេញលេញជាមួយអង្គការសង្គមស៊ីវិលនិងសាធារណជន។ ច្បាប់នេះត្រូវបានព្រាងឡើងដោយមានលក្ខណៈទូលំទូលាយពេក ដែលផ្តល់អំណាចដល់រដ្ឋាភិបាលក្នុងការរារាំងការចុះឈ្មោះអង្គការថ្មីៗ និងលុបឈ្មោះអង្គការដោយអំពើចិត្ត។ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ច្បាប់ទូរគមនាគមន៍ក៏បានអនុម័តផងដែរ ដែលផ្តល់ឲ្យរដ្ឋាភិបាលនូវអំណាចតាមដានយ៉ាងទូលំទូលាយ។ បន្ថែមពីនេះ ច្បាប់ពីរទៀតគឺច្បាប់សហជីព និងច្បាប់ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិតក៏គំរាមគំហែងបន្ថែមទៀតដល់

សេរីភាពខាងការបញ្ចេញមតិនិងខាងសមាគមផងដែរ។ ច្បាប់ទាំងនេះដើរតួឲ្យមានភាពស្របច្បាប់សម្រាប់ការគ្រប់គ្រងរបស់រដ្ឋាភិបាលទៅលើប្រព័ន្ធតុលាការ ព្រមទាំងធានាថាសំឡេងជំទាស់នឹងត្រូវស្ងាត់ស្ងៀម។

ការឃាយី ការចាប់ខ្លួន ការឃុំខ្លួន និងការកាត់ក្តីដោយអយុត្តិធម៌ទៅលើសកម្មជននៅកម្ពុជានៅតែបន្ត និងរឹតតែខ្លាំងៗឡើងនៅក្នុងឆ្នាំ២០១៥។ ទន្ទឹមនឹងនេះដែរ សកម្មជននិងអ្នកការពារសិទ្ធិមនុស្សកម្ពុជាជាច្រើនត្រូវបានចាប់ខ្លួនដោយអយុត្តិធម៌ក្នុងឆ្នាំ២០១៤ នៅតែជាប់បន្តក្នុងប្រព័ន្ធពន្ធនាគារដែលជាការជាប់ឃុំ និងរងចាំសវនាដោយមិនត្រឹមត្រូវ ។ ជាឧទាហរណ៍ នៅខែកុម្ភៈ ឆ្នាំ២០១៥ អាឡិចហ្គូហ្សាលេស ដាវិឌសុន ជាសកម្មជនបរទេសដែលធ្វើការក្នុងអង្គការមាតាធម្មជាតិធ្វើការខាងបរិស្ថាន ត្រូវរដ្ឋាភិបាលកម្ពុជាបណ្តេញចេញ ដោយមិនបន្តសុពលភាពទិដ្ឋាការ បន្ទាប់ពីការងារយុទ្ធនាការប្រឆាំងនិងការបូមខ្សាច់នៅខេត្តកោះកុង។ មុនពេលការចាប់ខ្លួន នាយករដ្ឋមន្រ្តី ហ៊ុន សែន បានគំរាមថានឹងបណ្តេញចេញអាឡិចចេញពីប្រទេស បើគាត់មិនបញ្ឈប់សកម្មភាពនេះទេ[1]។ យុវជនបីនាក់ធ្វើការនៅក្នុងអង្គការនេះដែរ ក៏ត្រូវបានចាប់ខ្លួននៅខែសីហា បន្ទាប់ពីបានចូលរួមការតវ៉ាដោយសន្តិវិធីទាក់ទងនឹងសកម្មភាពបូមខ្សាច់។ ឧទាហរណ៍មួយទៀតពាក់ព័ន្ធនឹងប្រធានសហគមន៍ជនជាតិដើមភាគតិចជង និងសកម្មជនបរិស្ថាន វ៉ែន វ៉ន ដែលត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ពាក់ពន្ធនឹងសកម្មភាពប្រមូលផ្តុំដោយសន្តិវិធីនៅឆ្នាំ២០១៥។ គាត់នៅតែបន្តឃុំខ្លួន បន្ទាប់ពីចាប់ខ្លួនចុងក្រោយនៅខែតុលាពាក់ព័ន្ធការចោទប្រកាន់រឿងកាប់ឈើ ទោះបីជាសមាជិកសហគមន៍ជនជាតិដើមភាគតិចមានសិទ្ធិប្រើប្រាស់ឈើសម្រាប់ការសាងសង់ក៏ដោយ[2]។

ឆ្នាំ២០១៥ គឺជាឆ្នាំបញ្ចប់បញ្ហានយោបាយរវាងគណបក្សកាន់អំណាចគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បន្ទាប់ពីទំនាស់ក្នុងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣។ ការបង្ក្រាបគណបក្សជំទាស់ត្រូវបានបង្ហាញឲ្យឃើញតាមរយៈសមាជិករបស់គណបក្សសង្គ្រោះជាតិមួយចំនួនត្រូវបានឃាយីដោយប្រព័ន្ធតុលាការ ការបង្ខំរត់គៀសខ្លួនចេញពីប្រទេស និងរងអំពើហិង្សាជាដើម។ ជាឧទាហរណ៍នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ សកម្មជនដែលពាក់ព័ន្ធនឹងគណបក្សសង្គ្រោះជាតិត្រូវបានកាត់ទោសជាប់ពន្ធនាគាររយៈពេលវែងដោយចាប់ពី៧ ទៅ២០ ឆ្នាំ ពីការចោទប្រកាន់ពីបទដឹកនាំកុបកម្ម ដោយសារតែពាក់ព័ន្ធនឹងបាតុកម្មនៅសួនសេរីភាពនារាជធានីភ្នំពេញនៅខែកក្កដា ឆ្នាំ២០១៤។ នៅដើមខែសីហា បន្ទាប់ពីរយៈពេលពីរថ្ងៃដែលនាយករដ្ឋមន្ត្រីបានអំពាវនាវឲ្យចាប់ខ្លួនបន្ថែមទៀត សកម្មជនគណបក្សសង្គ្រោះជាតិបីនាក់ផ្សេងទៀតត្រូវបានចោទប្រកាន់ពីបទចូលរួមចលនាកុបកម្មពាក់ព័ន្ធនឹងការបាតុកម្មដូចគ្នាផងដែរ។ សាលដីការនេះបង្ហាញឲ្យឃើញច្បាស់ពីកង្វះភស្តុតាង។ ជាងនេះទៅទៀត នៅថ្ងៃទី២៦ ខែតុលា នគរបាលបានខកខានក្នុងការរារាំងការវាយប្រហាររបស់អ្នកតវ៉ាប្រឆាំងនឹងគណបក្សសង្គ្រោះជាតិ ទៅលើតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិពីរនាក់គឺ

---

[1] តាត ឧត្តម មេ ទិដ្ឋារា Daniel Pye និង Griff Tapper "សកម្មជនដ៏ក្លាហានត្រូវបណ្តេញចេញ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ <http://bit.ly/1Rh7gUF> ។

[2] អូន ភាព និង Perter Ford "អ្នកតវ៉ាជ្រលងអារ៉ែងជាប់គុកពីបទចោទកាប់ឈើ" សារព័ត៌មានខេមបូឌាដេលី ថ្ងៃ០៨ ខែតុលា ឆ្នាំ២០១៥ <http://bit.ly/1VPqShX>។

ញឹក ប៊ុនធ័យ និងគង់ សុភា នៅខាងក្រៅរដ្ឋសភាជាតិ ដែលបង្ហាញយ៉ាងច្បាស់ថាការវាយប្រហារនេះគឺជាការរៀបចំដោយមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់។ នៅខែវិច្ឆិកា លោក សម រង្ស៊ី បានសម្រេចចិត្តចាកចេញពីកម្ពុជាម្តងទៀត បន្ទាប់មានដីការចាប់ខ្លួនពាក់ព័ន្ធនឹងករណីបរិហារកេរ្តិ៍តាំងពីឆ្នាំ២០០៨។ តាំងពីពេលនោះមក មានបទចោទប្រកាន់ជាច្រើនត្រូវបានចោទចំពោះលោក ហើយមកដល់បច្ចុប្បន្នគាត់ប្រឈមមុខនឹងជាប់ពន្ធនាគារជាច្រើនឆ្នាំ។

ខណៈដែលស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០១៥ នៅតែមានបញ្ហាជាច្រើន ក៏មានសញ្ញាណវិជ្ជមានមួយចំនួនផងដែរ ដូចជាពាក់ព័ន្ធសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា។ រដ្ឋាភិបាលបានបង្ហាញនិងបើកចំហចំពោះលទ្ធភាពក្នុងការអនុវត្តសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាក្នុងកំណែទម្រង់ច្បាប់និងសង្គមនៅឆ្នាំ២០១៥។ ឆ្លើយតបទៅនៅការលើករបស់ម.ស.ម.ក ទៅលើនិតិបញ្ញត្តិដែលផ្តល់សិទ្ធិស្មើគ្នាចំពោះសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាទៅលើអាពាហ៍ពិពាហ៍ភេទដូចគ្នា រដ្ឋាភិបាលបានឆ្លើយតបថា ការធ្វើឲ្យស្របច្បាប់នូវអាពាហ៍ពិពាហ៍ភេទដូចគ្នាគឺជាការបើកទូលាយ និងលើកទឹកចិត្តឲ្យក្រុមអ្នកស្រឡាញ់ភេទដូចគ្នាបន្តធ្វើយុទ្ធនាការ បើសិនជាពួកគេទាមទាឲ្យមានច្បាប់បែបនេះ[3]។ ទោះជាយ៉ាងណា អ្នកស្រឡាញ់ភេទដូចគ្នានៅតែប្រឈមនឹងការរើសអើងគួរឲ្យកត់សម្គាល់នៅក្នុងសហគមន៍។ តាមការស្រាវជ្រាវរបស់ម.ស.ម.ក ឆ្នាំ២០១៥ ស្តីពីអ្នកស្រឡាញ់ភេទដូចគ្នានៅសាលារៀនបានបង្ហាញថា ៦២,៧១% នៃអ្នកឆ្លើយតបអ្នកស្រឡាញ់ភេទដូចគ្នា បានរាយការណ៍ថាខ្លួនធ្លាប់រងប្រមាថមាក់ងាយ។ ក្នុងចំណោមអ្នកធ្លាប់រងប្រមាថមាក់ងាយ ៩៣,៥៩% អះអាងថាខ្លួនរងប្រមាថមាក់ងាយដោយសារតែនិន្នាការភេទឬអត្តសញ្ញាណនិងការបង្ហាញយេនឌ័រ។[4]

ឆ្នាំ២០១៦ ខាងមុខហើយនឹងគៀកទៅដល់ការបោះឆ្នោតថ្នាក់ជាតិនិងក្រោមជាតិ យើងរំពឹងថាលំហរប្រជាធិបតេយ្យនឹងកាន់តែរួមតូច ជាមួយការបង្កើនសម្ពាធពីសំណាក់រដ្ឋាភិបាលទៅលើសំឡេងជំទាស់ទាំងនយោបាយនិងក្រោយច្បាប់អង្គការមិនមែនរដ្ឋាភិបាលនិងសេចក្តីព្រាងច្បាប់ផ្សេងៗទៀត។ ទោះជាយ៉ាងណា ខណៈពេលដែលរដ្ឋាភិបាលមានបំណងរឹតបន្តឹងសេរីភាពមូលដ្ឋាន ដោយសារតែពលរដ្ឋកាន់តែចេះនិងយល់ដឹងសិទ្ធិរបស់ខ្លួន ប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីតស៊ូមតិ។ ដូច្នេះ យើងនៅតែមានសង្ឃឹមថាកម្ពុជាតាមកិច្ចខិតខំប្រឹងតស៊ូមតិជាសហគមន៍ ការងាររបស់សង្គមស៊ីវិល និងការដាក់សម្ពាធរបស់អន្តរជាតិ ប្រជាពលរដ្ឋគ្រប់រូបអាចនឹងរីករាយទទួលបានការគោរពសិទ្ធិមនុស្សស្មើភាពគ្នា។

## ២. ខណ្ឌនភាព

ក្នុងអំឡុងរយៈពេលនៃរបាយការណ៍ ម.ស.ម.ក បានចេញផ្សាយអត្ថបទចេញផ្សាយចំនួន៧២ រួមមានសេចក្តីថ្លែងការណ៍/វិចារណកថាព័ត៌មាន/លិខិតចំហចំនួន២៣ សេចក្តីថ្លែងការណ៍រួមចំនួន២៤ សេចក្តីប្រកាស

---

[3] សង្គមស៊ីវិលនិងធុរកិច្ចស្វាគមន៍រដ្ឋាភិបាលគាំទ្រសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានិងអំពាវនាវឲ្យមានភាពច្បាស់លាស់ចំពោះច្បាប់កម្ពុជា។ ថ្ងៃ២៨ ខែកញ្ញា ឆ្នាំ២០១៥ <http://bit.ly/1SRdxGh>។

[4] យូអ៊ីនឌីភី, "ជាអ្នកស្រឡាញ់ភេទដូចគ្នាក្នុងអាស៊ីៈ របាយការណ៍ប្រទេសកម្ពុជា (‘Being LGBT in Asia: Cambodia Country Report’) ឆ្នាំ២០១៤ <http://bit.ly/1liiB93>.

ព័ត៌មានបន្ទាន់គម្រោងអ្នកការពារសិទ្ធិមនុស្សឬ គម្រោងសេរីភាពបញ្ចេញមតិចំនួន៥ កំណត់ត្រាសង្ខេបចំនួន៥ របាយការណ៍បែបស្រាវជ្រាវចំនួន១ សលាកប័ត្រព័ត៌មានចំនួន២ វិភាគផ្នែកច្បាប់ចំនួន២ និងឯកសារផ្សេងៗទៀតចំនួន១០ (សេចក្តីប្រកាសព័ត៌មានចំនួន៥ លិខិតចំនួន៤ និងខិត្តបណ្ណចំនួន១)។ ឯកសារទាំងនេះចេញផ្សាយដើម្បីតស៊ូមតិ និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្សជាច្រើនរួមមានសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ សិទ្ធិជនភាគតិច និងផ្សេងៗទៀត។ ឯកសារចេញផ្សាយរបស់ម.ស.ម.ក បានជំរុញឲ្យអាជ្ញាធរឆ្លើយតបទៅនឹងការរំលោភសិទ្ធិមនុស្ស។ ឧទាហរណ៍នៅថ្ងៃទី៣០ ខែសីហា ម.ស.ម.ក បានចេញសេចក្តីថ្លែងការណ៍ទាមទាឲ្យមានការស៊ើបអង្កេតឲ្យបានត្រឹមត្រូវចំពោះករណីបាត់ខ្លួន ឃឹម សុផាត ជាការឆ្លើយតប ប្រធានអគ្គស្នងការនគរបាលជាតិបានស្នើឲ្យក្រុមគ្រួសាររបស់ឃឹម សុផាត ដាក់ពាក្យបណ្តឹងទៅនគរបាលជាតិ ដើម្បីផ្តល់ព័ត៌មានសំខាន់ៗដល់នគរបាលក្នុងការសម្របសម្រួលឲ្យមានការស៊ើបអង្កេតបន្ថែមទៀត។

បន្ថែមពីលើនោះ ម.ស.ម.ក បានរៀបចំកម្មវិធីវិទ្យុផ្សាយផ្ទាល់ចំនួន**១៦៩** ដែលក្នុងកិច្ចពិភាក្សានីមួយៗផ្តោតលើប្រធានបទខាងលើមួយឬច្រើន រួមទាំងមានប្រធានបទពាក់ព័ន្ធនឹងសិទ្ធិដីធ្លីចំនួន**១១** ធុរកិច្ចនិងសិទ្ធិមនុស្សចំនួន**៥** សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួន**១៨** សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាចំនួន១៣ និងអ្នកការពារសិទ្ធិមនុស្សជាស្ត្រីចំនួន៥ និងសេរីភាពមូលដ្ឋានចំនួន៣១ ។ ម.ស.ម.ក រៀបចំសិក្ខាសាលារួមគ្នាចំនួន២ ដង សិក្ខាសាលាពិគ្រោះយោបល់ស្តីពីច្បាប់អង្គការស៊ីវិល ១ និងច្បាប់ទទួលព័ត៌មាន១ ។ ម.ស.ម.ក រៀបចំវគ្គបណ្តុះបណ្តាលចំនួន២៩ នៅលើប្រធានបទ ផ្សេងៗដូចជាព័ត៌មានបច្ចេកវិទ្យា បណ្តាញសង្គម សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា សិទ្ធិដីធ្លី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ធុរកិច្ច និងសិទ្ធិមនុស្ស និងវិធានការសន្តិសុខសម្រាប់អ្នកការពារសិទ្ធិមនុស្ស។

ចំណុចដែលគួរឲ្យចាប់អារម្មណ៍មួយទៀត ម.ស.ម.ក បានរៀបចំយុទ្ធនាការចំនួន ៣ ដង។ ក្នុងឱកាសទិវានារីអន្តរជាតិ ម.ស.ម.ក រៀបចំយុទ្ធនាការនៅថ្ងៃទី០៦ ខែមីនា ដើម្បីទាមទារឲ្យដោះលែងអ្នកជាប់ឃុំទាំង ១២ នាក់ រួមមានស្ត្រី១១ នាក់និងព្រះសង្ឃមួយអង្គដែលត្រូវបានកាត់ទោសនិងជាប់គុក ខណៈពេលខ្លួនតវ៉ាប្រឆាំងនឹងការរំលោភដីធ្លី។ ដើម្បីស្នើសុំរដ្ឋាភិបាលដើម្បីបញ្ឈប់ជំរុញនូវដំណើរការច្បាប់ និងស្នើឲ្យមានកិច្ចពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធពាក់ព័ន្ធច្បាប់អង្គការមិនមែនរដ្ឋាភិបាល ម.ស.ម.ក បានចូលរួមយុទ្ធនាការស្តីពី"បញ្ឈប់ហើយពិគ្រោះយោបល់" ជាមួយអង្គការសង្គមស៊ីវិលផ្សេងទៀត។ ដើម្បីចូលរួមទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មានលើកទី២ របស់អង្គការសហប្រជាជាតិ ម.ស.ម.ក បានរៀបចំយុទ្ធនាការអំពី "មិនអាចបំភ្លេច" នៅថ្ងៃទី០២ វិច្ឆិកា ដែលមានគោលបំណងបង្ហាញពីវប្បធម៌និទណ្ឌភាពនៅកម្ពុជា ដែលរំលឹកដល់រដ្ឋាភិបាលនិងសាធារណជនកុំឲ្យភ្លេច ជនរងគ្រោះនិងគ្រួសាររបស់ពួកគេជាច្រើនរបស់កម្ពុជា។ ម.ស.ម.ក បានដាក់តាំងបង្ហាញរូបថតរបស់ជនរងគ្រោះនៃនិទណ្ឌភាពនៅកម្ពុជាចំនួន១០ នាក់រយៈពេល១ សប្តាហ៍នៅហ្វេស ស៊ី ស៊ី រាជធានីភ្នំពេញ ហើយក៏បានផលិតវិដេអូស្តីពីនិទណ្ឌភាពផងដែរ។

**៣. សកម្មភាពដែលដំណើរការបានល្អ និងមិនល្អ**

ជោគជ័យមួយចំនួនពាក់ព័ន្ធសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាកើតឡើងតាមរយៈគម្រោងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងទំនោរយេនឌ័រ។ ឧទាហរណ៍ ប្រតិកម្មរបស់រាជរដ្ឋាភិបាលចំពោះការតស៊ូមតិជាបន្តបន្ទាប់ទៅលើសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានលើកទឹកចិត្ត ដែលនេះបញ្ជាក់ពីភាពវិជ្ជមាននិងការបើកទូលាយចំពោះអាពាហ៍ពិពាហ៍ភេទដូចគ្នា ដែលជាការគាំទ្របញ្ជាក់ដោយលោក ផៃ ស៊ីផាន អ្នកនាំពាក្យរបស់រដ្ឋាភិបាល និងការចូលរួមជាវិជ្ជមានជាមួយនឹងសេចក្តីថ្លែងការណ៍របស់ ម.ស.ម.ក គឺជាចំណុចគួរឲ្យកត់សម្គាល់។ ជាងនេះទៅទៀត របាយការណ៍យុវជនអ្នកស្រឡាញ់ភេទដូចគ្នារងការប្រមាថមាក់ងាយនៅសាលារៀនក៏ត្រូវបានទទួលស្គាល់ថាមានប្រយោជន៍សម្រាប់អ្នកធ្វើគោលនយោបាយ សង្គមស៊ីវិលនិងក្រសួងអប់រំ យុវជននិងកីឡា ពីព្រោះថារបាយការណ៍នេះបានទាញចំណាប់អារម្មណ៍ធ្វើយ៉ាងណាដើម្បីការពារសិស្សដែលជាអ្នកស្រឡាញ់ភេទដូចគ្នាពីសកម្មភាពប្រមាថមាក់ងាយឲ្យកាន់តែប្រសើរឡើង។

ក្នុងអំឡុងបេសកកម្ម ម.ស.ម.ក បានជួបបញ្ហាប្រឈមមួយចំនួនដែលរារាំងក្នុងការអនុវត្តគម្រោងឲ្យទទួលបានលទ្ធផល។ ជាឧទាហរណ៍ នៅពេលគម្រោងធុរៈកិច្ចនិងសិទ្ធិមនុស្សចង់សម្ភាសអ្នកតំណាងក្រុមហ៊ុនឯកជនដែលពាក់ព័ន្ធនឹងទំនាស់ដីធ្លីសម្រាប់ការស្រាវជ្រាវរបស់ខ្លួននៅខែកញ្ញា ក្រុមហ៊ុនចំនួន៣ បានបដិសេធជួបជាមួយនឹងក្រុមការងាររបស់ម.ស.ម.ក ឬមិនឆ្លើយតបតែម្តង។ បន្ថែមពីនេះ បញ្ហាប្រឈមចេញពីអាជ្ញាធរក្នុងអំឡុងចុះបេសកកម្ម។ ជាឧទាហរណ៍ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ បន្ទាប់ពីក្រុមការងារបានចុះដល់ភូមិចក់ចា ឡានរបស់ក្រុមការងារត្រូវបានបញ្ឈប់នៅប៉ុស្តិ៍នគរបាលត្រួតពិនិត្យស្រុកអូររាំងក្នុងខេត្តមណ្ឌលគីរី។ អាជ្ញាធរបានបញ្ជាឲ្យអ្នកបើកបរចុះចេញពីឡាន ដើម្បីឆែកឆេររកអាវុធនៅក្នុងឡាន។ ជាទូទៅ ម.ស.ម.ក យល់ថាគោលដៅនិងសកម្មភាពរបស់គម្រោងនៅតែជាក់ស្តែងនិងអាចសម្រេចបាន។

**៤. មេរៀន**

ម.ស.ម.ក យល់ថាការតស៊ូព្យាយាមក្នុងការងារតស៊ូមតិអាចផ្តល់នូវលទ្ធផលមួយចំនួន។ ឧទាហរណ៍ បន្ទាប់ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលត្រូវបានអនុម័តនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ នេះ ម.ស.ម.ក បានសរសេរលិខិតចំហទៅកាន់ក្រសួងមហាផ្ទៃ ដើម្បីស្នើសុំការបញ្ជាក់ទាក់ទិននឹងការអនុវត្តច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលចំពោះសហគមន៍តាមមូលដ្ឋាននិងក្រុមមិនក្រៅប្រព័ន្ធ។ លិខិតចំហនេះបានដាក់ជូនក្រសួងបន្ទាប់ពីម.ស.ម.ក ទទួលបានព័ត៌មានអំពីការអនុវត្តច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលដើម្បីហាមប្រាមសហគមន៍តវ៉ានៅក្នុងខេត្តក្រចេះ។ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ក្រសួងបានឆ្លើយតបនឹងម.ស.ម.ក ព្រមទាំងបញ្ជាក់ថាច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលនេះមិនអនុវត្តចំពោះក្រុមសហគមន៍តូចៗ ដូចជាគ្រួសារនៅក្នុងឃុំខ្សឹមនោះទេ។ តែលិខិតបានបញ្ជាក់ថាមន្រ្តីមូលដ្ឋាននៅខេត្តក្រចេះនៅតែធ្វើត្រូវចំពោះការប្រាប់ដល់សហគមន៍ថាត្រូវតែចុះបញ្ជី ពីព្រោះពួកគាត់គឺជាសហគមន៍ជនជាតិដើមភាគតិចដើម្បីទទួលបាននូវប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ម.ស.ម.ក សូមស្វាគមន៍ចំពោះការឆ្លើយតបជាវិជ្ជមានពីក្រសួងមហាផ្ទៃ ជាពិសេសការបំភ្លឺបញ្ជាក់ទៅលើការអនុវត្តន៍ឲ្យបានត្រឹមត្រូវរបស់ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលចំពោះសហគមន៍តាមមូលដ្ឋាន។ ទោះជាយ៉ាងណា ម.ស.ម.ក ជឿជាក់ថាករណីនៅឃុំខ្សឹម នេះទាមទារឲ្យមានការបំភ្លឺបន្ថែមទៀត។

ជាចុងក្រោយ ការផលិតវិដេអូ សម្រាប់ជាឯកសារបង្រៀនត្រូវការពេលវេលាច្រើន លើសពីអ្វីដែលរំពឹងទុក ដោយសារតែបញ្ហាបច្ចេកទេសនិងភាពស្មុគស្មាញនៃព័ត៌មានដែលត្រូវប្រមូលយកមកផងដែរ។

**៥. គោលការណ៍ផ្ដោតលើយេនឌ័រ និងសិទ្ធិជាមូលដ្ឋាន**

ម.ស.ម.ក បានខិតខំប្រឹងប្រែងធានាឲ្យមានសមភាពយេនឌ័រក្នុងស្ថាប័ន ដែលមានបញ្ចូលក្នុងកម្មវិធីនិងគម្រោងទាំងអស់របស់ខ្លួន។ ក្នុងអំឡុងការអនុវត្តគម្រោង ម.ស.ម.កបានខិតខំជំនះឲ្យមានការចូលរួមពីស្ត្រីដូចជាការរៀបចំកម្មវិធីត្រូវធានាឲ្យមានតំណាងបុរសនិងស្ត្រីជាវាគ្មិនក្នុងព្រឹត្តិការណ៍ផ្សេងៗ និងក្នុងគ្រប់ឱកាសផ្សេងៗបានលើកឡើងពីស្ថានភាពស្មើគ្នាស្របតាមច្បាប់រវាងបុរសនិងស្ត្រីលើបញ្ហាសិទ្ធិមនុស្ស។

ក្នុងនាមជាមេដឹកនាំសហគមន៍ឬសកម្មជនសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្សជាស្ត្រីដើរតួយ៉ាងសំខាន់ក្នុងការលើកស្ទួយ ពង្រឹងនិងការពារសិទ្ធិមនុស្ស។ ម.ស.ម.ក បានកត់សម្គាល់ដោយក្ដីបារម្ភណ៍ថាអ្នកការពារសិទ្ធិមនុស្សជាស្ត្រីទទួលរងនូវការរំលោភបំពាន រួមទាំងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រដែលជាឫសគល់នៃការប្រតិបត្តិដោយការរើសអើង និងបទដ្ឋានសង្គមដែលនាំឲ្យមានអំពើហិង្សាលើស្ត្រី។ ដូចនេះគម្រោងអ្នកការពារសិទ្ធិមនុស្សជាស្ត្រីមានគោលបំណងពង្រឹងភាពអង់អាចក្លាហាន ព្រមទាំងផ្តល់សេវាគាំទ្រផ្នែកច្បាប់ ផ្លូវចិត្តនិងសប្បុរសធម៌ផងដែរទៅដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីដែលទទួលរងនូវអំពើហិង្សា ការឃាយីបៀតបៀននិងការគំរាមគំហែងដោយសារតែការងាររបស់ខ្លួនផងដែរ៕

---ចប់---